ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សង្ខេបកិច្ចប្រជុំ

# ពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

រៀបចំដោយ: អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## ១.សេចក្តីផ្តើម

យោងតាមអាណត្តិ និងបេសកកម្មដែលកំណត់ដោយច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តម្រូវឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន២ដង ក្នុងមួយឆ្នាំ ដើម្បីពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការគាំទ្រជានយោបាយ ក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួល និងជួយចូលរួមដោះស្រាយរាល់ឧបសគ្គ ការលំបាក និងចំណុចខ្វះខាតនានា ពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្រ គោលនយោបាយ សេចក្តីប្រកាស និងសេចក្តីសម្រេចនានា ដែលបានរៀបចំ និងស្នើដោយក្រុមប្រឹក្សាបច្ចេកទេសនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឆ្លើយតបនឹងការលើកឡើងខាងលើ នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក-លោកស្រី ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងក្រសួង-ស្ថាប័ន ទាំង៣៣ រាជធានី-ខេត្តទាំង២៥ តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ចំនួន១៧០រូប ដោយមានការឧបត្ថម្ភគាំទ្រពីថវិកាជាតិ។

## ២.គោលបំណង នៃកិច្ចប្រជុំពេញអង្គ

- ជម្រាបជូនសមាជិក សមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពីបច្ចុប្បន្នភាពនៃស្ថានភាពរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។
- ជម្រាបជូនសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។
- ពិនិត្យមើលនូវសមិទ្ធផល នៃការអនុវត្តសកម្មភាពការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុង៦ខែ ដើមឆ្នាំ២០២២។
- ពិនិត្យពីឧបសគ្គ ការលំបាក និងចំណុចខ្វះខាត ក្នុងការអនុវត្តសកម្មភាពកន្លងមក
- ស្នើសុំការអនុម័តនូវសេចក្តីសម្រេចចិត្ត របស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ប្រចាំឆ្នាំ២០២២។

## ៣. កម្មវិធីនៃកិច្ចប្រជុំពេញអង្គ

កិច្ចប្រជុំពេញអង្គបានប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម៖

- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសហេតុ គោលបំណង និងរបៀបវារៈនៃកិច្ចប្រជុំ

- សុន្ទរកថាបើកកិច្ចប្រជុំ ដោយ **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រលើកទី៥ បង្ហាញដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បទបង្ហាញ ស្តីពីការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្ការ នៃការចម្លងមេរោគអេដស៍ជាសកល បង្ហាញដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បទបង្ហាញស្តីពីការសម្របសម្រួលបញ្ចប់អេដស៍ ឆ្នាំ២០២៥ បង្ហាញដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សម្របសម្រួល និងដឹកនាំដោយ **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ពិភាក្សា និងអនុម័តសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២២។
- សុន្ទរកថាបិទអង្គប្រជុំដោយ **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ៤.ដំណើរការប្រព្រឹត្តទៅនៃកិច្ចប្រជុំ



ជាកិច្ចចាប់ផ្តើម **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានថ្លែងសុន្ទរកថាស្វាគមន៍និងបើកកិច្ចប្រជុំ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានស្វាគមន៍ ជាមួយនឹងសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងការដឹកនាំ «**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ឆ្នាំ២០២២**» ដោយផ្ទាល់ ក្រោយពីខកខានក្នុងជំនួបបែបនេះ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៩ មកដោយសារតែមានការគំរាមកំហែងពីជំងឺកូវីដ-១៩ ដែលបានបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពសុខភាព នយោបាយ សេដ្ឋកិច្ច ក្នុងទូទាំងតំបន់ និងពិភពលោកទាំងមូល។

មកទល់ពេលនេះ និយាយដោយឡែកស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ ក្នុងព្រះរាជាណាចក្រកម្ពុជារបស់យើងបានធ្លាក់ចុះ និងធូរស្រាលយ៉ាងច្រើនឈានទៅរកប្រក្រតីភាពស្ទើរទាំងស្រុង ដែលបានទទួលការសាទរ និងគាំទ្រយ៉ាងខ្លាំង ពីសំណាក់ប្រជាជនគ្រប់មជ្ឈដ្ឋានទាំងក្នុង និងក្រៅប្រទេស ហើយឈរក្នុងលំដាប់ជាប្រទេសឆ្នើម និងមានស្នាដៃល្អក្នុងចំណោមប្រទេសដែលបានទទួលជោគជ័យក្នុងការទប់ស្កាត់ការចម្លងរាតត្បាតជំងឺកូវីដ-១៩ នៅលើពិភពលោក ហើយដែលសមិទ្ធផលដ៏ធំធេងគួរជាទីមោទនភាពនេះ គឺពិតជាបានមកពីកិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងមិនចេះ

នឿយហត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចប្រកបដោយគតិបណ្ឌិត ដាក់ចេញនូវយុទ្ធសាស្ត្រវ៉ាក់សាំង និងវិធានការទប់ស្កាត់ ដ៏សមស្រប ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយនៃការរាតត្បាតមេរោគកូវីដ-១៩ លើសុខភាពសាធារណៈ ដោយរក្សាបាននូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ច សុខមាលភាពសង្គមរបស់យើងបានយ៉ាងរឹងមាំ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គដោយផ្ទាល់នាពេលនេះ។

ជាមួយគ្នានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះក្រសួង ស្ថាប័ន រាជធានី ខេត្ត ពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូដែលបានខិតខំប្រឹងប្រែងចូលរួមអនុវត្តការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ រហូតទទួលបានលទ្ធផលជាផ្លែផ្កា ឆ្លើយតបនឹងស្មារតីនៃ «សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស» ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីវិធានការ៦ចំណុច ឆ្ពោះទៅកាន់ចីរភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់រាជរដ្ឋាភិបាលកម្ពុជា ដែលការងារនេះបាននឹងកំពុងអនុវត្តបន្តដើម្បីឈានឆ្ពោះទៅសម្រេចបាននូវគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចប់អេដស៍នៅឆ្នាំ២០២៥។





**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមគម្រោងផែនការសកម្មភាពឆ្នាំ២០២២ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃនេះ គឺជាកិច្ចប្រជុំលើកទី១ ដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាព ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់រយៈពេល៦ខែ ដើមឆ្នាំ២០២២នេះ ដើម្បីធ្វើការប្រមូលជាតុចូល និងអនុសាសន៍មួយចំនួន តាមរយៈការចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកានៃកិច្ចប្រជុំ។ កិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈ ចំនួនបីរួមមាន ៖

ទី១. បទបង្ហាញស្តីពី របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្រ្តលើកទី៥ បង្ហាញជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ទី២. បទបង្ហាញស្តីពីការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្ការ នៃការចម្លងមេរោគអេដស៍ជាសកល បង្ហាញដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ទី៣. បទបង្ហាញស្តីពីការសម្របសម្រួលបញ្ចប់អេដស៍ ឆ្នាំ២០២៥ បង្ហាញជូនដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

បន្ទាប់មកក៏នឹងមានការពិភាក្សារួមគ្នា ព្រមទាំងដាក់ចេញនូវសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២។

ក្នុងឱកាសនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់ជូនកិច្ចប្រជុំពេញអង្គថា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រួមជាមួយដៃគូពាក់ព័ន្ធ បាននឹងកំពុងតែធ្វើដំណើររួមគ្នា ប្រកបដោយទស្សនវិស័យច្បាស់លាស់ ក្នុងក្តីសង្ឃឹមពិតប្រាកដ ឆ្ពោះទៅរកការលុបបំបាត់ជំងឺអេដស៍ ដោយសារតែប្រទេសកម្ពុជាយើង មានការប្តេជ្ញាចិត្ត និងមានការគាំទ្រជានយោបាយដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ រួមជាមួយគ្នានេះផងដែរ យើងមានចីរភាព នៃការចូលរួមជាពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងជាពិសេសបណ្តាញអ្នកផ្ទុកមេរោគអេដស៍។ យើងទាំងអស់គ្នា បង្កើតបាននូវ ស្ថាប័នដឹកនាំគ្រប់គ្រង និងសម្របសម្រួលតែមួយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស យើងមានផែនការយុទ្ធសាស្រ្តជាតិតែមួយ មានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏មានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ ដែលនឹងផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តការអនុវត្ត ការងារឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងពេលខាងមុខឱ្យស្រប ទៅតាមអនុសាសន៍ និងសេចក្តីសម្រេចចិត្តដែលនឹងផ្តល់ជូន និងដាក់ចេញ ដើម្បីអនុម័តក្នុងកិច្ចប្រជុំពេញអង្គនាពេលបន្តិចទៀតនេះ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ការងារពីបណ្តាសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានបញ្ចប់សុន្ទរកថា និងសង្ឃឹមថា សមាជិក សមាជិកានៃកិច្ចប្រជុំ នឹងចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងបានប្រកាសបើក "កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២ "។

១.បទបង្ហាញរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រលើកទី៥ បង្ហាញជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖



**ឯកឧត្តម** បានជម្រាបជូនពីបច្ចុប្បន្នភាពនៃស្ថានភាពរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ក្នុងឆ្នាំ២០២០ អត្រាឆ្លងមេរោគអេដស៍គឺ ០.៦% ក្នុងចំណោមប្រជាជនទូទៅ មានអ្នកឆ្លងថ្មី ចំនួន១.១០០នាក់ ស្លាប់ចំនួន១២០០នាក់។ ចំពោះគោលដៅបញ្ចប់អេដស៍ ៩៥-៩៥-៩៥ នាឆ្នាំ២០២៥ ប្រទេសកម្ពុជា បានបង្ហាញពីភាពជោគជ័យក្នុងឆ្លើយតបនឹងមេរោគអេដស៍ ដោយ៩៥ ទីមួយ សម្រេចបាន ៨៤% ៩៥ ទីពីរ សម្រេចបាន ៩៩% ចំណែកឯ ៩៥ ទីបី សម្រេចបាន ៩៧%។

បន្ទាប់មក **ឯកឧត្តមបណ្ឌិត** ក៏បានបង្ហាញពីលទ្ធផលនៃការអនុវត្តសកម្មភាពទៅតាមយុទ្ធសាស្ត្រនីមួយៗ នៅក្នុងផែនការយុទ្ធសាស្ត្រលើកទី៥។

**ឯកឧត្តមបណ្ឌិត** ក៏បានបង្ហាញរបាយការណ៍ស្តីពីសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ពីក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍ ដែលបង្ហាញ ពីការចូលរួមជាពហុវិស័យ ពិសេសកាកបាទក្រហមកម្ពុជា តាមរយៈក្រុមការងារឥស្សរៈជនឆ្នើមថ្នាក់ជាតិ។ ចំពោះសេវាផ្តល់ថ្នាំប្រឆាំងមេរោគអេដស៍ដោយសហគមន៍(Community ART services Delivery)ដែលអនុវត្តដោយអង្គការខាន់ណា ជាការផ្តួចផ្តើមថ្មីមួយទៀតក្នុងការសម្រួលឱ្យអ្នកទទួលសេវា ទទួលបានទាំងសេវាផង និងប្រសិទ្ធភាពផង (ឯកសារលម្អិតមានភ្ជាប់មកជាមួយ)។

២. បទបង្ហាញស្តីពីការរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្ការ នៃការចម្លងមេរោគអេដស៍ជាសកល បង្ហាញជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

**ឯកឧត្តមបណ្ឌិត** បានបង្ហាញថា អនុក្រឹត្យស្តីពីការបង្ការនៃការចម្លងមេរោគអេដស៍ជាសកល មាន៦ជំពូក និង១៤មាត្រា ក្នុងនោះ រួមមាន៖

- ជំពូកទី១ ស្តីពីបទបញ្ញត្តិទូទៅ មាន២មាត្រា
- ជំពូកទី២ ស្តីពីតួនាទីគ្រប់គ្រង មាន១មាត្រា
- ជំពូកទី៣ ស្តីពីវិធានការក្នុងការគ្រប់គ្រងការចម្លងមេរោគអេដស៍ មាន៣មាត្រា
- ជំពូកទី៤ ស្តីពីវិធានការ ក្នុងការគ្រប់គ្រងឧបករណ៍សម្ភារប្រើប្រាស់ និងកាកសំណល់អាចចម្លងមេរោគអេដស៍ មាន៥មាត្រា
- ជំពូកទី៥ ស្តីពីទោសបញ្ញត្តមាន ១មាត្រា និង

○ ជំពូកទី៦ ស្តីពីអវសានប្បញ្ញត្តិ មាន២មាត្រា (ឯកសារលម្អិតភ្ជាប់មកជាមួយ)។

៣. បទបង្ហាញស្តីពីការសម្របសម្រួលបញ្ចប់អេដស៍ឆ្នាំ២០២៥ បង្ហាញជូនដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖



**ឯកឧត្តមវេជ្ជបណ្ឌិត** បានបញ្ជាក់ថា អ្នកបាត់មុខដែលយើងប៉ាន់ស្មានមានចំនួន ១២.០០០នាក់ ប្រមាណ១៦% ដោយពន្យល់ក្នុងអាថ៌កំបាំងនៃអ្នកផ្ទុកមេរោគអេដស៍ថា បើគិតជាចំនួនឬតួលេខ គឺដដែល ប៉ុន្តែបើគិតជាមនុស្សមានអត្តសញ្ញាណផ្សេងៗគ្នា។ **ឯកឧត្តម** ក៏បានសង្កត់ធ្ងន់ថា ស្ថានភាពចម្លងមេរោគអេដស៍ មានសភាពខ្លាំងក្លាចំពោះអ្នកដែលទើបឆ្លងថ្មីៗ មានអត្រាមេរោគអេដស៍ មួយលានកូពី ក្នុងមួយមីលីម៉ែត្រគូបឈាម។ ក្រុមបុរសរួមភេទជាមួយបុរសមួយចំនួន មិនបានដឹងថាខ្លួនប្រឈមការឆ្លងមេរោគអេដស៍ និងមិនចង់ប្រើប្រាស់ស្រោមអនាម័យ ដែលបណ្តាលឱ្យពួកគាត់ប្រឈមនឹងការឆ្លងជំងឺ កាមរោគ ពិសេសមេរោគអេដស៍។

**ឯកឧត្តមវេជ្ជបណ្ឌិត** បានបញ្ជាក់បន្ថែមទៀតថា ផែនការយុទ្ធសាស្ត្ររបស់អង្គការសហប្រជាជាតិ មានលក្ខណៈស្របគ្នាជាមួយផែនការយុទ្ធសាស្ត្រជាតិ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ការសម្របសម្រួលឈានទៅដល់ការបញ្ចប់អេដស៍ គឺឈរលើគោលការណ៍បីមួយ គឺស្ថាប័នសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រជាតិតែមួយ និងប្រព័ន្ធតាមដាន វាយតម្លៃតែមួយ ព្រមទាំងត្រូវសម្របសម្រួល ដោយប្រើយន្តការជាលក្ខណៈពហុវិស័យ អនុវត្តសកម្មភាពតាមភូមិសាស្ត្រអាទិភាព ដោយប្រើប្រាស់ធនធានឱ្យអស់តិចបំផុត និងមានប្រសិទ្ធផលខ្ពស់ និងដោយគោរពតាមភាពជាអ្នកដឹកនាំ ភាពជាដៃគូ និងវិនិយោគ ដែលផ្តោតលើផលប្រយោជន៍អ្នកទទួលផលជាធំ (People Centered Approach)។

## ៥. មតិយោបល់សមាជិកកិច្ចប្រជុំពេញអង្គ

**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានប្រសាសន៍ថា ការឆ្លើយតបនឹងមេរោគអេដស៍ ជាការងារពហុវិស័យ និងត្រូវធ្វើដូចប្រសាសន៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** «ការងារអេដស៍ធ្វើសកម្មភាពប្រៀបដូចមនុស្សម្នាក់រង្គើពីក្បាលដល់ចុងជើង» **ឯកឧត្តម** ក៏បញ្ជាក់បន្ថែមទៀតថា អ្នកជំងឺអេដស៍ មិនដូចជាអ្នកជំងឺធម្មតា ដែលស្វែងរកកន្លែងផ្តល់សេវា



និងទៅទទួលសេវាទេ ហេតុដូច្នេះ ទើបក្រុមការងារប្រយុទ្ធនឹងមេរោគអេដស៍ខិតខំស្វះស្វែងរកគ្រប់មធ្យោបាយ ដើម្បីជំរុញពួកគាត់ ដែលលាក់មុខ និងភាពខ្មាសអៀន ឱ្យមកទទួលសេវាឱ្យបានទៀងទាត់។ ម្យ៉ាងវិញទៀត ការឆ្លងតាមរយៈការរួមភេទដោយមានដៃគូច្រើន នៅតែជាក្តីបារម្ភ និងប្រុងប្រយ័ត្នខ្ពស់ ពីព្រោះឆ្លងដោយសារការសប្បាយទាក់ទងផ្លូវភេទ។

ការងារស្វែងរកអ្នកបាត់មុខមិនមកទទួលសេវាចំនួន១២.០០០នាក់នេះត្រូវបន្ត ប៉ុន្តែប្រសិនបើរកមិនឃើញវិញនោះ យើងត្រូវទប់ស្កាត់ការឆ្លងថ្មីតាមគោលដៅតិចជាង១នាក់ក្នុងមួយថ្ងៃ ដែលបច្ចុប្បន្ននេះ ស្ថិតនៅក្នុងកម្រិត២នាក់ក្នុងមួយថ្ងៃនៅឡើយទេ។ ករណីឆ្លងថ្មីនៅតែខ្ពស់ ក្នុងឆ្នាំ២០១៨ មានប្រហែលជា១,០០០នាក់ នឹងបានកើនរហូតដល់១,១០០នាក់ ក្នុងឆ្នាំ២០១៩។ ឥរិយាបទផ្លូវភេទរបស់យុវវ័យ និងក្រុមបុរសរួមភេទជាមួយបុរស បានបង្កើតជាហានិភ័យនៃការចម្លងរាលដាលសកម្ម




ឡើងវិញ។

**ឆ្លងកាត់ការពិភាក្សាគ្នា កិច្ចប្រជុំបាន៖**

១.ឯកភាពលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រលើកទី៥ ។

២.ឯកភាពកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្ការនៃការចម្លងមេរោគអេដស៍ជាសកល ទៅជា "អនុក្រឹត្យស្តីពីវិធានការក្នុងការបង្ការ និងគ្រប់គ្រងការចម្លងមេរោគអេដស៍តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ"។

៣.ចំពោះសេចក្តីព្រាងសេចក្តីសម្រេចចិត្ត កិច្ចប្រជុំបានកែសម្រួល៖

- ចំណុចទី១៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើបន្ថែមពាក្យ «គម្រោងថវិកា»
- ចំណុចទី២៖ ក្រសួងទេសចរណ៍ ស្នើបន្ថែមពាក្យ «ឧស្សាហកម្មសណ្ឋាគារ»
- ចំណុចទី៣៖ក្រសួងប្រៃសណីយ៍ បានស្នើលុបពាក្យ «លើកទឹកចិត្ត» ប៉ុន្តែអង្គប្រជុំសម្រេចរក្សាទុកពាក្យលើកទឹកចិត្តដដែលវិញ
- ចំណុចទី៤៖អង្គប្រជុំស្នើបន្ថែមពាក្យ«មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក»
- ចំណុចទី៥៖ អង្គប្រជុំស្នើបន្ថែមពាក្យ »ក្រសួងសុខាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ»

- ចំណុចទី៦៖ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ស្នើឱ្យមានការចូលរួមស្វែងរកអ្នកបាត់មុខ១២,០០០នាក់នេះ ទាំងអស់គ្នា ចំណែកក្រសួងព័ត៌មានស្នើកែសម្រួលទៅជា«ក្រសួងស្ថាប័ន ពាក់ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ»
- ចំណុចទី៧៖ អង្គប្រជុំស្នើសុំបន្ថែមពាក្យ «អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អង្គការសហគមន៍»
- ចំណុចទី៨៖ ស្នើលុបពាក្យ «ប្រព័ន្ធប្រទេស(Country System)» កែសម្រួលជា «ជួយពង្រឹងសមត្ថភាពស្ថាប័ន»
- ចំណុចទី៩៖ រក្សាទុកដដែល។

## ៧.អនុម័ត លើសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គ៖

ឆ្លងកាត់ការពិភាក្សា សមាជិក សមាជិកា នៃកិច្ចប្រជុំពេញអង្គបានអនុម័តលើសេចក្តីសម្រេចចិត្តដែលមានខ្លឹមសារដូចខាងក្រោម៖



១. ជំរុញលើកទឹកចិត្តដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្ត បន្តដំណើរការលើកផែនការសកម្មភាព និងថវិកាស្របតាមផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣ ដោយផ្តោតលើអនុសាសន៍នៃការវាយតម្លៃផែនការយុទ្ធសាស្ត្រពាក់កណ្តាលអាណត្តិ និងស្របតាមអាណត្តិការងាររបស់ស្ថាប័នសាមី និងសូមការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២. បន្តជំរុញលើកទឹកចិត្តក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជំរុញអនុវត្តគោលនយោបាយស្រោមអនាម័យ១០០ភាគរយ នៅតាមកន្លែងផ្សេងៗ ដូចជា សណ្ឋាគារ បៀរហ្គាដិន ខារ៉ាអូខេ និងទីកន្លែងកម្សាន្តនានា។

៣. លើកទឹកចិត្តក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យជំរុញការផ្តល់សេវាបង្ការ ការពារ ថែទាំ កាត់បន្ថយការចម្លងមេរោគអេដស៍ ពីមាតាទៅទារកឱ្យបានតាមគោលដៅកំណត់។

៤. ជំរុញការរៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ឃុំ សង្កាត់ ដោយបញ្ចូលសមាសភាពពាក់ព័ន្ធនានា តំណាងអ្នកផ្ទុកមេរោគអេដស៍ តំណាងប្រជាជនគន្លឹះ បន្ថែមទៅក្នុងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក.)។

៥. បន្តជំរុញលើកទឹកចិត្តមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល រៀបចំវិធីសាស្ត្រ និងមធ្យោបាយប្រកបដោយនវានុវត្តន៍ និងបរិយាប័ន្ន ដើម្បីឱ្យក្រុមប្រជាជនគន្លឹះ ៩៥ភាគរយ ទទួលបាននូវសេវាបង្ការចម្រុះ ឱ្យចៀសផុតពីការឆ្លងមេរោគអេដស៍។

៦. ជំរុញលើកទឹកចិត្តក្រសួងសុខាភិបាល (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ) រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បន្តស្វែងរក និងបញ្ចុះបញ្ចូលឱ្យអ្នកផ្ទុកមេរោគអេដស៍ប្រមាណ១២.០០០នាក់ ដែលមិនទាន់មកទទួលសេវាព្យាបាល ឱ្យមកទទួលធ្វើតេស្តរកមេរោគអេដស៍ ដើម្បីទទួលបានសេវាថែទាំ និងព្យាបាលឱ្យបានទាន់ពេល។

៧. ជំរុញលើកទឹកចិត្តក្រសួងសុខាភិបាល (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ) ពង្រីកតំបន់គ្របដណ្តប់ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាប្រើប្រាស់វិធីលេបថ្នាំបង្ការទុកជាមុន នៅពេលប្រព្រឹត្តប្រឈមនឹងការចម្លងមេរោគអេដស៍ (Pre-exposure prophylaxis: PrEP) ដល់ប្រជាជនគន្លឹះ។

៨. ស្នើសុំមូលនិធិសកល (Global Fund) តាមរយៈគណៈកម្មាធិការសម្របសម្រួលជំនួយមូលនិធិសកលដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់នៅកម្ពុជា (CCC) និងដៃគូអភិវឌ្ឍទាំងអស់ ជួយពង្រឹងប្រព័ន្ធជាតិ (Country System) ដែលផ្តួចផ្តើមដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឆ្ពោះទៅសម្រេចចីរភាពកម្មវិធីអេដស៍នៅកម្ពុជា។

៩. ជំរុញដល់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគាំពារសង្គម រៀបចំគោលនយោបាយជាតិស្តីពីកិច្ចសន្យាសង្គម (Social contracting) ដើម្បីអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ បន្តជួយធ្វើអន្តរាគមន៍លើការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលចាំបាច់មួយចំនួនតទៅអនាគត ។

ជាកិច្ចបញ្ចប់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានថ្លែងសុន្ទរកថាបិទកិច្ចប្រជុំ ដោយបានបង្ហាញចំណាប់អារម្មណ៍ថា ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈការធ្វើបទបង្ហាញរួមជាមួយនឹងការពិភាក្សា ផ្តល់យោបល់យ៉ាងផុសផុល ធ្វើឱ្យកិច្ចប្រជុំទទួលបាននូវលទ្ធផលគួរជាទីមោទនៈ ស្របទៅនឹងកម្មវត្ថុ ដោយក្នុងនោះ អង្គប្រជុំៈ

- បានអនុម័តជាគោលការណ៍នូវរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលក្នុងការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ រយៈពេល៦ខែដើមឆ្នាំ២០២២។
- បានអនុម័តសេចក្តីព្រាងអនុក្រឹត្យស្តីពី វិធានការក្នុងការបង្ការ និងគ្រប់គ្រងការចម្លងមេរោគអេដស៍ តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ។
- ការបន្តជំរុញឱ្យមានវឌ្ឍនភាព និងការបន្តការអនុវត្ត «សេចក្តីជូនដំណឹងលេខ២១៣ សជណ.សស» ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

- ការអនុម័តសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២ សម្រាប់បន្តអនុវត្តក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្ពោះទៅសម្រេចបាននូវគោលដៅ៩៥-៩៥-៩៥ នាឆ្នាំ២០២៥។
- សូមអបអរសាទរចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួម និងផ្តួចផ្តើមឱ្យមានកិច្ចប្រជុំនានា ដើម្បីឆ្លើយតបនឹង«សេចក្តីជូនដំណឹងលេខ២១៣សជណ.សស» ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្រ្តី ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលមកទល់ពេលនេះ យើងទទួលបាននូវលទ្ធផលជាវិជ្ជមាន ក្នុងការសម្របសម្រួល ក៏ដូចជាការរៀបចំនីតិវិធី ប្រើប្រាស់ថវិកា៨០លានរៀល សម្រាប់រាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងខេត្តបន្ទាយមានជ័យ។
- សូមលើកទឹកចិត្តក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបន្តជួយបង្កើន និងសម្របសម្រួលដល់ការផ្តល់ និងប្រើប្រាស់កញ្ចប់ថវិកាជាតិ ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់បណ្តាខេត្តដែលមានហានិភ័យដ៏ទៃទៀត។
- សូមលើកទឹកចិត្តគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ឱ្យបន្តជំរុញ និងចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្ត «សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស» ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្រ្តី ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។
- កង្វះខាតថវិកានៅតែជាបញ្ហាចម្បងមួយ រារាំងដល់ការអនុវត្តផែនការសកម្មភាពឱ្យបានពេញលេញទៅតាមការគ្រោងទុក ឬក៏លទ្ធភាពក្នុងការពង្រីកអត្រាគ្របដណ្តប់ទៅកាន់ក្រុមគោលដៅថ្មីជាពិសេសក្រុមប្រជាជនគន្លឹះ។

ជាមួយគ្នានេះផងដែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែលម្អសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពនាពេលខាងមុខ។
- ជំរុញ និងប្រើប្រាស់គ្រប់យន្តការទាំងអស់ ដើម្បីធ្វើឱ្យសម្រេចបានជោគជ័យក្នុងការអនុវត្ត «សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស» ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- ប្រឹងប្រែងអនុវត្តសេចក្តីសម្រេចចិត្តនៃសម័យប្រជុំពេញអង្គ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺ អេដស៍លើកទី១ ឆ្នាំ២០២២ ដែលទើបបានទទួលការអនុម័តនាពេលនេះ។

- បន្តជំរុញ និងលើកទឹកចិត្តក្រសួង ស្ថាប័ន ដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យលើកសំណើថវិកាឆ្នាំ២០២៣ ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួង ស្ថាប័នសាមី ឱ្យបានព្រមៗគ្នា។
- បន្តជំរុញការអនុវត្តបន្ត រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីសម្រេចឱ្យបានជោគជ័យ នូវគំនិតផ្ដួចផ្ដើម ទីក្រុងរួមគ្នាពន្លឿនការឆ្លើយតបការរីករាលដាលជំងឺអេដស៍ ( Fast-Track Cities Initiative ) ដែលបាន និងកំពុងដំណើរការនៅក្នុងទីក្រុងភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។
- លើកទឹកចិត្តជូនខេត្តចំនួន១១ បន្ថែមទៀតឱ្យរៀបចំផែនការសកម្មភាព និងថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- លើកទឹកចិត្តក្រសួងផែនការ ក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បន្តធ្វើការសហការ ជំរុញ និងកែសម្រួល នូវកម្មវិធីគ្រួសារក្រីក្រ ដោយផ្ដល់ប័ណ្ណក្រីក្រ ដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ជាបុគ្គលនៅតាម ART sites និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធកម្មវិធីគ្រួសារក្រីក្រថ្នាក់ជាតិរបស់ក្រសួងផែនការ។
- បន្តរុករកអ្នកដែលមិនទាន់បានមកទទួលសេវា ឱ្យមកទទួលយកសេវា បង្កើនការគ្របដណ្ដប់ និងផ្ដល់អន្តរាគមន៍ឱ្យមានប្រសិទ្ធភាព ទៅលើក្រុមប្រឈម ពិសេសក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ដោយបង្កើនតំបន់គ្របដណ្ដប់កម្មវិធី PrEP ឱ្យបានកាន់តែមានប្រសិទ្ធភាព។
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេស សម្រាប់បន្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ទៅមុខទៀត រហូតសម្រេចបានជោគជ័យក្នុងការលុបបំបាត់ជំងឺអេដស៍ជាស្ថាពរ ជាពិសេសគ្រប់គ្រងឱ្យបានទាំងស្រុង ក្រុមប្រជាជនគន្លឹះ ដែលតម្រូវឱ្យមានកម្មវិធីឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ ដូចដែលយើងបានធ្វើចំពោះ ក្រុមនារីបម្រើសេវាកម្សាន្តសប្បាយនៅតាមគ្រឹះស្ថាននានាផងដែរ។

ជាកិច្ចបញ្ចប់កិច្ចប្រជុំពេញអង្គ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់នាពេលនេះ។ តាមរយៈការចូលរួមពីសមាជិក សមាជិកាយ៉ាងសកម្ម ផ្ដល់នូវគំនិតល្អៗ រួមជាមួយមតិដ៏ល្អ និងមានតម្លៃ នាំឱ្យយើងអាចយកទៅប្រើប្រាស់ក្នុងការកែលម្អក្នុងការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមមួយកម្រិតទៀត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះ ឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវផ្លែផ្កាគួរជាទីមោទនៈ នាពេលនេះ។

ជាទីបញ្ចប់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ នូវពុទ្ធពរទាំងឡាយ បួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព និងបានប្រកាសបិទ "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២**" ប្រកបដោយភាពជោគជ័យ។

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

វេជ្ជបណ្ឌិត **ហ្វូត សេរីរដ្ឋ**

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់

**អគ្គលេខាធិការ**

បណ្ឌិត **ឈឹម ឃិនដារ៉ែត**

បានឃើញ និងឯកភាព

**ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង មូលី**